រដ្ឋសភា
ចូល លេខ ៦១៦០
ថ្ងៃទី ១៨/១១ ឆ្នាំ ២០១៩ ម៉ោង ១៧:០០
បញ្ជូនទៅ T. D

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

# របបសន្តិសុខសង្គម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .. គោលបំណង**

ច្បាប់នេះមានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឲ្យមានសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។

**មាត្រា២ .. គោលដៅ**

ច្បាប់នេះមានគោលដៅកំណត់អំពីគោលការណ៍ទូទៅ បែបបទ យន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។

**មាត្រា៣ .. វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងអស់ដូចខាងក្រោម៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈរួមមាន៖

- មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- មន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ លើកលែងផ្នែកប្រាក់សោធន
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ
- មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ចំពោះតែតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងផ្នែកថែទាំសុខភាព
- មន្ត្រីដែលបម្រើការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងអាជ្ញាធរសេវនកម្មជាតិ
- អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ
- បុគ្គលនៃវិស័យសាធារណៈផ្សេងទៀត ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣. បុគ្គលស្វ័យនិយោជន៍។

ច្បាប់នេះមិនមានវិសាលភាពអនុវត្តលើយោធិននៃកងយោធពលខេមរភូមិន្ទ ដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤.- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានកំណត់និយមន័យដូចមានចែងនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម

**មាត្រា៥.- ផ្នែកប្រាក់សោធន**

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋនិងបុគ្គលនៃវិស័យសាធារណៈមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦.- ផ្នែកថែទាំសុខភាព**

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋ បុគ្គលនៃវិស័យសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧.- ផ្នែកហានិភ័យការងារ**

របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវា

សមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជក ត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៨ .- ផ្នែកនិកម្មភាពការងារ**

របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ច ដែលនិយោជកនិងកម្មករនិយោជិតត្រូវមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៩ .- ចំណែកនៃភាគទានសម្រាប់របបភាគទានជាកាតព្វកិច្ច**

ចំណែកនៃភាគទានរបស់បុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិត នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះសម្រាប់របបភាគទានជាកាតព្វកិច្ច ក្នុងផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព និងនិកម្មភាពការងារមិនត្រូវលើសពី៥០%(ហាសិបភាគរយ)នៃ ភាគទានសរុបឡើយ។

ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទានត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា១០ .- ក្រុមប្រឹក្សាជាតិគាំពារសង្គម**

រាល់ប្រតិបត្តិការសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និង តម្រង់ទិសក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវកំណត់ដោយ ព្រះរាជក្រឹត្យ។

**មាត្រា១១ .- និយ័តករសន្តិសុខសង្គម**

ត្រូវបានបង្កើតនិយ័តករសន្តិសុខសង្គមដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

១. កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ វិធានចាំបាច់នានា និងគោលការណ៍ណែនាំស្តីពីវិនិយោគមូលនិធិសន្តិសុខសង្គម។

២. តាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។

៣. បង្កើតយន្តការការពារសមាជិកនិងផ្សះផ្សាវិវាទនៅពេលមានទំនាស់។

៤. ត្រួតពិនិត្យអនុលោមភាព ដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១២ .- បេឡាជាតិសន្តិសុខសង្គម**

បេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា **ប.ស.ស.** ជាស្ថាប័នប្រតិបត្តិករ តែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

**ប.ស.ស.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបង្កើតដោយព្រះរាជក្រឹត្យ ស្ថិត ក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិត ក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។